**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការសម្រាប់សិក្សា និងសាងសង់វិមានអនុស្សាវរីយ៍**
**នយោបាយ ឈ្នះ ឈ្នះ និងការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា**
អនុគណៈកម្មការសាងសង់ស្តូប ឈ្នះ ឈ្នះ ខេត្តកោះកុង "អ.គ.ក."
លេខ: ០១ សស.ង

# សេចក្តីអំពាវនាវ

អនុគណៈកម្មការសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ ខេត្តកោះកុង មានកិត្តិយសសូមជម្រាបជូនសម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា អស់លោក លោកស្រី មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ប្រជាពលរដ្ឋ ពាណិជ្ជករ វិនិយោគិន និងសប្បុរសជន មេត្តាជ្រាបថា ជាការអរគុណសន្តិភាព អរគុណនយោបាយ ឈ្នះ ឈ្នះ ដឹងគុណចំពោះអគ្គស្ថាបនិក និងប្រតិបត្តិករអនុវត្តនយោបាយ ឈ្នះ ឈ្នះ ព្រមទាំងយុទ្ធជន យុទ្ធនារី ដែលបានបូជាសាច់ស្រស់ ឈាមស្រស់ ដើម្បីស្វែងរកសន្តិភាព ធ្វើឲ្យប្រទេសជាតិមានការរីកចម្រើនលើគ្រប់វិស័យ នាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានអនុញ្ញាតជូនគណៈកម្មការសម្រាប់សិក្សា និងសាងសង់វិមានអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ និងការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា ចាប់ផ្តើមសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ ខេត្តកោះកុង ។

ដើម្បីអនុគណៈកម្មការសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ ខេត្តកោះកុង ដំណើរការសាងសង់ សម្រេចបានជោគជ័យតាមការគ្រោងទុក អនុគណៈកម្មការសូមអំពាវនាវសម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា អស់លោក លោកស្រី មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ប្រជាពលរដ្ឋ ពាណិជ្ជករ វិនិយោគិន និងសប្បុរសជន សូមមេត្តាចូលរួមឧបត្ថម្ភគាំទ្រជាថវិកា តាមលទ្ធភាពជាក់ស្តែង ។

អំណោយដ៏សប្បុរសទាំងនេះ សូមមេត្តាជូនមកខុទ្ទកាល័យ**សម្តេចពិជ័យសេនា ទៀ បាញ់** ឬទំនាក់ទំនងតាមរយៈឯកឧត្តម ឧត្តមសេនីយ៍ឯក **ជា វណ្ណា** ទីប្រឹក្សា**សម្តេចពិជ័យសេនា ទៀ បាញ់** និងជាប្រធានក្រុមការងារជានា នៃអនុគណៈកម្មការសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ ខេត្តកោះកុង នៅរៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ។

អនុគណៈកម្មការសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ ខេត្តកោះកុង មានជំនឿយ៉ាងមុតមាំចំពោះទឹកចិត្តដ៏សប្បុរសរបស់សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា អស់លោក លោកស្រី មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ប្រជាពលរដ្ឋ ពាណិជ្ជករ វិនិយោគិន និងសប្បុរសជន ពិតជាចូលរួមគាំទ្រលើកទឹកចិត្តដល់ការសាងសង់សំណង់ប្រវត្តិសាស្ត្រជាតិនេះ មានការអភិវឌ្ឍន៍ជានិរន្តរ៍ ។

សូមសម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា អស់លោក លោកស្រី មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ប្រជាពលរដ្ឋ ពាណិជ្ជករ វិនិយោគិន និងសប្បុរសជន ទទួលនូវអំណរគុណទុកជាមុន ។

ថ្ងៃអង្គារ ៤រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២០

**អនុគណៈកម្មការសាងសង់ស្តូបអនុស្សាវរីយ៍**
**នយោបាយឈ្នះ ឈ្នះ ខេត្តកោះកុង**

ទូរស័ព្ទទំនាក់ទំនង ៖
- ឯកឧត្តម ជា វណ្ណា 097 8 999 999 - ឯកឧត្តម ស្រេង ហុង 097 7 831 906
- កញ្ញា សេង ច័ន្ទពិសី 078 92 99 66 - លោក លឹម សាវ៉ាន់ 097 7 282 828